# អនុស្សរណៈកិច្ចព្រមព្រៀង

រវាង

# **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

## (**គម្រោង** CoWES)

និង

# **អង្គការម្លប់បៃតង**

លេខសម្គាល់ : MAFF/CoWES/2018/001-00

ចំណងជើងគម្រោងសំណើ : ពង្រឹងផលិតភាពដីកសិកម្ម និងសហគមន៍ព្រៃឈើ នៅឃុំ តាសាល ត្រពាំងជោង (ស្រុកឱរ៉ាល់) និងឃុំក្រាំងដីវ៉ាយ (ស្រុកភ្នំស្រួច) ខេត្តកំពង់ស្ពឺ។

ឈ្មោះស្ថាប័នអនុវត្ត : អង្គការម្លប់បៃតង

អាសយដ្ឋាន : ផ្ទះលេខ១៩៤ ផ្លូវ៣៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

កាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ : ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៨ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

## ១. សាវតា

គម្រោង ការគ្រប់គ្រងរួមគ្នាដើម្បីការពារ និងស្តារសេវាកម្មទីជម្រាល និងប្រព័ន្ធបរិស្ថាននៅតំបន់ជួរភ្នំក្រវាញ (ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត) ឬហៅកាត់ថា៖ CoWES ត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយសម្ពាធការប្រើប្រាស់ដីធ្លីក្នុងតំបន់មួយចំនួន ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោតតាមរយៈ ការង្ហាញឲ្យឃើញពីកិច្ចសហការណ៍គ្រប់គ្រងដីកសិកម្ម និងស្តារតំបន់ព្រៃឡើងវិញ រួមជាមួយនឹងកិច្ចជម្រុញការគ្រប់គ្រងដីធ្លីដោយចីរភាព និងរក្សាលំនឹងមុខងាររបស់អាងរងទឹកភ្លៀង នៅតំបន់វិចវិលមួយចំនួន នៅប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត ក្នុងខេត្តកំពង់ស្ពឺ។

គម្រោងមានគោលបំណងដើម្បីសម្រេចឲ្យបានសមាសភាគចំនួន៣ គឺ៖

- ការអភិរក្សដីស្រែ និងពង្រឹងការអនុវត្តកសិ-រុក្ខកម្ម
- ការស្តារឡើងវិញ និងគ្រប់គ្រងដោយចីរភាពតំបន់ព្រៃសហគមន៍
- ការពង្រឹងសមត្ថភាពការគ្រប់គ្រង និងការពិនិត្យតាមដានក្នុងតំបន់អាងស្តុកទឹក (ផ្ទៃរងទឹកភ្លៀង) នៅប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត

ដើម្បីសម្រេចបានលទ្ធផលបន្ទាប់ (ឬសមាសភាគ) ទាំងបីខាងលើ គម្រោងបានលើកឡើងនូវសកម្មភាពជាគន្លឹះមួយចំនួនដូចខាងក្រោម៖

- ណែនាំអំពីការគ្រប់គ្រងដី និងទឹកឲ្យមាននិរន្តរភាពនៅក្នុងតំបន់កសិផល
- អនុវត្តសាកល្បង កសិ-រុក្ខកម្ម នៅក្នុងតំបន់គម្រោង នៃស្រុកចំនួន២ ដើម្បីជួយបង្កើតសួនដំណាំចម្រុះ (ជ្រើសរើសពូជដំណាំ ឬរុក្ខជាតិដែលស្របនឹងស្ថានភាពដី)
- ពង្រឹងការគ្រប់គ្រងព្រៃសហគមន៍អោយមាននិរន្តរភាព (ដើម្បីធ្វើជាគំរូ)
- កំណត់ និងផ្តល់ ឬជួយធ្វើអោយប្រសើរឡើងដល់ចីរភាពជីវភាព
- ការពង្រឹងសមត្ថភាពដល់ភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីការពារព្រៃឈើ និងការអនុវត្តច្បាប់
- ពិនិត្យមើល និងបង្កើតអោយមានករណីសិក្សា និងការអនុវត្តល្អទៅលើការគ្រប់គ្រងអាងស្តុកទឹក ផ្តល់ការគាំទ្រតាមរយៈការសិក្សាលម្អិតលើការវាយតម្លៃប្រព័ន្ធអេកូឡូស៊ីក្នុងមូលដ្ឋានដើម្បីផ្តល់ជាព័ត៌មានស្តីពីផែនការប្រើប្រាស់ដី

យោងតាមឯកសារគម្រោង (ដែលបានចុះហត្ថលេខានាថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៧) គម្រោង CoWES មានរយៈពេល៣ឆ្នាំដែលចាប់ផ្តើមជាផ្លូវការពីខែកក្កដា ឆ្នាំ២០១៧ ហើយបញ្ចប់ក្នុងខែ កក្កដា ឆ្នាំ២០២០។

យោងស្មារតី នៃអង្គសិក្ខាលាផ្តើមអនុវត្តគម្រោងនាថ្ងៃទី ១៥-១៦ ខែធ្នូ ឆ្នាំ២០១៧ (នៅសណ្ឋាគារដាយមិន ខេត្តព្រះសីហនុ) និងកិច្ចប្រជុំលើកទី១ របស់គណៈកម្មការដឹកនាំ និងតម្រង់ទិសគម្រោង ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ (នៅសណ្ឋាគារហូលីដេ ខេត្តកំពង់ស្ពឺ) បានកំណត់លទ្ធផលរំពឹងទុកចំនួន ៧ (ក្រោមសមាសភាគទាំង៣-Outcomes) ដើម្បីសម្រេចឲ្យបានក្នុងអំឡុងពេល៣ឆ្នាំ នៃគម្រោង។ លទ្ធផលរំពឹងទុកទាំង៧ រួមមាន៖

***<u>សមាសភាគទី ១ GEF ៖ ការអភិរក្សដីស្រែ និងពង្រឹងការអនុវត្តកសិ-រុក្ខកម្ម</u>***

លទ្ធផលទី១.១៖ អាទិភាពនៃការគ្រប់គ្រងដីដោយនិរន្តរភាព ត្រូវបានបញ្ជ្រាប ក្នុងផែនការរបស់អាជ្ញាធរ មូលដ្ឋាន ដោយសហការណ៍ជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ និងដៃគូ

លទ្ធផលទី១.២៖ អនុវត្តបង្ហាញអំពីការគ្រប់គ្រងដីដោយនិរន្តរភាព ផ្តោតលើក្រុមកសិករមានដីតិច (ទំហំតូច)

លទ្ធផលទី១.៣៖ អនុវត្តបង្ហាញអំពីការប្រើប្រាស់ដីឲ្យបានត្រឹមត្រូវ (សមស្រប) ដោយផ្តោតលើក្រុម កាន់កាប់ដីទំហំមធ្យម និងទំហំធំ (ក្រុមហ៊ុនកសិ.ឧស្សាហកម្មទទួលសិទ្ធស្របច្បាប់)។

***<u>សមាសភាគទី ២</u>៖ ការស្តារឡើងវិញ និងគ្រប់គ្រងដោយចីរភាពតំបន់ព្រៃសហគមន៍***

លទ្ធផលទី២.១៖ សកម្មភាពជាអាទិភាពដើម្បីពន្លឿនការអនុវត្តសកម្មភាពរបស់សហគមន៍ព្រៃឈើ ត្រូវបានរំលេចក្នុងផែនការរបស់អាជ្ញាធរមូលដ្ឋាន និងកម្មវិធីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លទ្ធផលទី២.២៖ អនុវត្តបង្ហាញពីយុទ្ធសាស្ត្រសមស្របក្នុងការស្តារព្រៃឈើ និង សហគ្រាសបង្កើតមុខ របរចិញ្ចឹមជីវិត

***<u>សមាសភាគទី ៣ </u>៖ ការពង្រឹងសមត្ថភាពការគ្រប់គ្រង និងការពិនិត្យតាមដានក្នុងតំបន់អាងស្តុកទឹក (ផ្ទៃរងទឹកភ្លៀង) នៅប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត***

លទ្ធផលទី៣.១៖ អភិវឌ្ឍន៍សមត្ថភាពដល់ស្ថាប័នពាក់ព័ន្ធសំខាន់ៗ ដើម្បីរៀបចំ និងអនុវត្តកម្មវិធី និងសកម្មភាពរួមគ្នាក្នុងការគ្រប់គ្រងទីជម្រាល

លទ្ធផល ទី៣.២ ៖ ត្រួតពិនិត្យ និងវាយតម្លៃ ដោយមានការចូលរួម ដើម្បីគាំទ្រកម្មវិធីដែលបានព្រមព្រៀង

អនុស្សរណៈនេះ រៀបចំឡើង ដោយយោង និងអនុលោមតាមអនុសាសន៍ដែលបានផ្តល់ដោយទីប្រឹក្សាអន្តរជាតិ ផ្តើមអនុវត្តគម្រោង សិក្ខាសាលាផ្តើមអនុវត្តគម្រោង (ថ្ងៃទី១៥-១៦ ខែធ្នូ ឆ្នាំ២០១៧) និងកិច្ចប្រជុំគណៈកម្មការដឹកនាំ និងតម្រង់ទិសគម្រោង (ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨) សំដៅការពង្រឹង និងកសាងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាន នៅក្នុងស្រុកគោលដៅគម្រោង (ស្រុកភ្នំស្រួច និង ស្រុកឱរ៉ាល់) ដើម្បីធ្វើសកម្មភាព និងបង្កើតលទ្ធផលគម្រោង ពិសេសសមាសភាគ ទី១ និងទី២ នៅឯមូលដ្ឋានផ្ទាល់។ តាមរយៈអនុស្សរណៈនេះ អង្គការមិនរដ្ឋាភិបាល (ដែលជាដៃគូរបស់រដ្ឋាភិបាល) នឹងដើរតួនាទីឈានមុខយ៉ាងសំខាន់នៅមូលដ្ឋាន (ឃុំនិងស្រុកគោលដៅ) ជាប្រតិបត្តិករឈរជាជួរមុខ ធ្វើសកម្មភាពជាប្រចាំជាមួយអាជ្ញាធរមូលដ្ឋាន (ឃុំ ស្រុក) ខេត្ត សហគមន៍ ពលរដ្ឋព្រមទាំងជួយសម្រួលការងារជាមួយស្ថាប័នពាក់ព័ន្ធ ពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ នាយកដ្ឋានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រី ឬទីប្រឹក្សាគម្រោង ក្នុងការគាំទ្រដល់សកម្មភាពនៅមូលដ្ឋានឲ្យទទួលបានជោគជ័យ។

អនុស្សរណៈ នេះមានវិសាលភាពស្របតាមគម្រោងសំណើ និងសកម្មភាពនានាដែលមានចែងក្នុងគម្រោងសំណើ ឬផែនការសកម្មភាព និងថវិកា ហើយមានភាពប្រទាក់ក្រឡា និងស៊ីសង្វាក់គ្នាជាមួយឯកសារ ក្របខ័ណ្ឌលទ្ធផល ផែនការ៣ឆ្នាំ និងផែនការប្រចាំឆ្នាំ នៃគម្រោង CoWES ។

## ២. គោលការណ៍ទូទៅ

២.១. អនុស្សរណៈនេះត្រូវបានធ្វើឡើងនៅ **ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៨** រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ជាស្ថាប័នអនុវត្តគម្រោង CoWES) ដែលបន្ទាប់ពីនេះទៅហៅកាត់ថា "**ក្រសួងកសិកម្ម**" និង **អង្គការម្លប់បៃតង** ដែលបន្ទាប់ពីនេះ ទៅហៅកាត់ថា "**ម្លប់បៃតង**"។

២.២. អនុស្សរណៈនេះមានរយៈពេលអនុវត្តចំនួន ២៤ខែ គិតចាប់ពី **ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៨ ដល់ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០**។

២.៣. អនុស្សរណៈនេះមានភ្ជាប់ជាមួយនូវសំណើរបស់អង្គការម្លប់បៃតង ដែលគម្រោងសំណើមានតារាង សកម្មភាព ថវិកា និងពេលវេលាជាក់លាក់។

២.៤. **ក្រសួងកសិកម្ម** នឹងវិភាជន៍ថវិកាសរុបចំនួន USD ២៤១.០២៨.០០ (ពីររយសែសិបមួយពាន់ និងម្ភៃប្រាំបីដុល្លារសហរដ្ឋអាមេរិកគត់) ដែលជាការវិភាជន៍តាមត្រីមាសដល់**ម្លប់បៃតង** ដើម្បីបង្កើតលទ្ធផល និងអនុវត្តផែនការសកម្មភាព និងថវិការបស់ខ្លួន ដូចមានចែងនៅក្នុងឯកសារគម្រោងសំណើ បន្ទាប់ពីចុះហត្ថលេខាលើអនុស្សរណៈជាផ្លូវការ។ ការវិភាជន៍សម្រាប់ត្រីមាសបន្តបន្ទាប់ នឹងត្រូវធ្វើឡើង បន្ទាប់ពីអនុវត្តសកម្មភាពឬចំណាយយ៉ាងតិច ៨០%នៃថវិកាដែលបានវិភាជន៍ផ្ទេរពីលើកមុន។ ការវិភាជន៍ផ្ទេរលើកចុងក្រោយចំនួន១០% នៃថវិកាសរុប នឹងត្រូវធ្វើឡើងនៅពេលដែលសកម្មភាពទាំងអស់បានបញ្ចប់ ទទួលបានរបាយការណ៍បញ្ចប់គម្រោង និងជម្រះបញ្ជីគណនេយ្យរួចរាល់។

២.៥. ក្នុងអំឡុងពេលអនុវត្តសកម្មភាពក្រោមកិច្ចសន្យាបន្តជាមួយ**ក្រសួងកសិកម្ម** (គម្រោង CoWES) នេះ បុគ្គលិក ឬស្ថាប័នទទួលកិច្ចសន្យាបន្តទាំងនេះ មិនត្រូវចាត់ជាបុគ្គលិក ឬស្ថាប័នរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិឡើយ ដូច្នេះកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិមិនទទួលខុសត្រូវចំពោះគ្រោះថ្នាក់ សុវត្ថិភាពការងារ សន្តិសុខ ឬទូទាត់លើសំណងដែលទាមទារដោយបុគ្គលិក ឬអង្គភាពទាំងនេះឡើយ ដែលអ្វីទាំងអស់នេះ គឺស្ថិតនៅក្រោមការទទួលខុសត្រូវ និងបន្ទុកផ្ទាល់របស់ **ម្លប់បៃតង**។

២.៥. **ម្លប់បៃតង** (ទាំងបុគ្គល ឬស្ថាប័នដែលទទួលកិច្ចសន្យាបន្ត) ក្រោម**ក្រសួងកសិកម្ម** ត្រូវមានគណនេយ្យភាព និងការទទួលខុសចំពោះមុខជាមួយ**ក្រសួងកសិកម្ម**។

## ៣. អំពីការគ្រប់គ្រងហិរញ្ញវត្ថុ និងការប្រើប្រាស់

៣.១. **ម្លប់បៃតង** ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិកាឲ្យបានត្រឹមត្រូវ ធានាបាននូវ គណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់។

៣.២. គោលនយោបាយគ្រប់គ្រង និងប្រតិបត្តិការរបស់អង្គការសាមី (**ម្លប់បៃតង**) នឹងត្រូវអនុវត្តនៅក្នុងការប្រើប្រាស់មូលនិធិដែលបានផ្តល់នេះ។

៣.៣. ដើម្បីជម្រុញដល់ការអនុវត្តសកម្មភាព និងការប្រើប្រាស់ថវិកាអោយបានត្រឹមត្រូវ **ក្រសួងកសិកម្ម (ក្រុមការងារគម្រោង)** នឹងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ **ម្លប់បៃតង** តាមរយៈមន្ត្រីគាំទ្រគម្រោង និងទីប្រឹក្សាគម្រោងជូនដល់ **ម្លប់បៃតង** តាមតម្រូវការជាក់ស្តែង។

៣.៤. រាល់ការប្រើប្រាស់មូលនិធិរបស់គម្រោង **ម្លប់បៃតង** ត្រូវធានាថាមូលនិធិនេះត្រូវបានប្រើប្រាស់ចំទិសដៅ ដូចមានចែងក្នុងតារាងផែនការសកម្មភាព និងថវិកាដែលបានឯកភាព ។

៣.៥. **ម្លប់បៃតង** ត្រូវធានាថា មូលនិធិនេះមិនមែនជាកម្មវត្ថុនៃការប្រើប្រាស់សម្រាប់ជាប្រយោជន៍បុគ្គលមានដូចជាការខ្ចីផ្ទាល់ខ្លួន ការយកមូលនិធិសម្រាប់ចងការប្រាក់ ឬការបុរេប្រទានសម្រាប់សកម្មភាពផ្សេងក្រៅពីសកម្មភាពដែលបានកំណត់ក្នុងផែនការសកម្មភាព និងថវិកាក្នុងឯកសារគម្រោងឡើយ។

## ៤. ការទទួលខុសត្រូវរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៤.១. **ក្រសួងកសិកម្ម** ត្រូវផ្ទេរមូលនិធិជាលក្ខណៈបុរេប្រទានទៅកាន់គណនីរបស់**ម្លប់បៃតង** ផ្អែកតាមផែនការសកម្មភាព និងថវិកាជាក់ស្តែង។ ការផ្ទេរថវិកានេះត្រូវធ្វើឡើងយ៉ាងយូរពីរសប្តាហ៍បន្ទាប់ពីទទួលបានសំណើសុំផ្ទេរថវិកាជាផ្លូវការពី**ម្លប់បៃតង** ។ ចំពោះនីតិវិធីផ្ទេរថវិកា គឺអនុវត្តដូចមានចែងក្នុងចំណុច ២.៤។

៤.២. ផ្តល់រាល់ទម្រង់បែបបទ នីតិវិធី ប្រព័ន្ធ ការគាំទ្រ ជំនួយបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាព ដែលត្រូវការចាំបាច់សម្រាប់ការរៀបចំតាក់តែង ការកសាងផែនការ ការតាមដាន ត្រួតពិនិត្យ និងការរៀបចំរបាយការណ៍របស់**ម្លប់បៃតង**។

៤.៣. តាមដានត្រួតពិនិត្យការអនុវត្តសកម្មភាព និងល័ក្ខខ័ណ្ឌនានា ដើម្បីធានាឱ្យមានភាពសមស្របជាមួយនឹងគម្រោងសំណើ និងអនុស្សរណៈនេះ។

៤.៤. ធ្វើការសិក្សា និងវាយតម្លៃការអនុវត្តសកម្មភាពជាទៀងទាត់ ដែលក្នុងនោះរួមទាំងការស្នើសុំឱ្យមានការផ្ដល់យោបល់ពីស្ថាប័នអនុវត្តនានា ក្នុងគោលបំណងសិក្សារៀនសូត្រអំពីចំណុចខ្លាំង និងចំណុចខ្សោយនៃកិច្ចដំណើរការអនុវត្តគម្រោង ។

## ៥. ការទទួលខុសត្រូវរបស់ម្លប់បៃតង

៥.១. **ម្លប់បៃតង** ត្រូវមានគណនេយ្យភាពចំពោះ **ក្រសួងកសិកម្ម (គម្រោង CoWES)** និង **ម្ចាស់ជំនួយ (UNDP/GEF)** លើការអនុវត្តសកម្មភាពដែលលំអិត ក្នុងគម្រោងសំណើនេះ (ឬផែនការសកម្មភាព និង ថវិកា) ។

៥.២. **ម្លប់បៃតង** ត្រូវអនុវត្តតាមគោលការណ៍ណែនាំនានាដែលបានផ្ដល់ជូន និងត្រៀមផ្ដល់ជូននាពេលខាងមុខដែលរួមមាន ប្រព័ន្ធតាមដាន និងវាយតម្លៃ ទម្រង់របាយការណ៍ប្រចាំខែ ត្រីមាស ការគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធគណនេយ្យលទ្ធកម្ម ។ល។

៥.៣. រៀបចំផែនការសកម្មភាព និងថវិកាប្រចាំត្រីមាស និងសំណើសុំផ្ទេរថវិកាមកកាន់ **ក្រសួងកសិកម្ម (គម្រោង CoWES)**។ ចំពោះនីតិវិធីផ្ទេរថវិកា គឺអនុវត្តដូចមានចែងក្នុងចំណុច ២.៤។

៥.៤. រៀបចំរបាយការណ៍វឌ្ឍនភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ដោយធ្វើការប្រៀបធៀបរវាងសកម្មភាព និងលទ្ធផលដែលសម្រេចបានជាក់ស្ដែង រួចផ្ញើមក **ក្រសួងកសិកម្ម (គម្រោង CoWES)** ឲ្យបានទៀងទាត់ ពេលគឺៈ របាយការណ៍ប្រចាំត្រីមាសត្រូវផ្ញើយ៉ាងយូរត្រឹមសប្ដាហ៍ទី១ នៃត្រីមាសបន្ទាប់ ។

៥.៥. ផ្ដល់ព័ត៌មានដល់ **ក្រសួងកសិកម្ម (គម្រោង CoWES)** ជាប្រចាំ ក្នុងពេលដែលការអនុវត្តណាមួយមិនអាចសម្រេចបានតាមការគ្រោងទុក និងក្នុងពេលដែលយល់ ឃើញថាសកម្មភាព ឬលទ្ធផលណាមួយមិនអាចសម្រេចបានតាមគោលបំណង ឬលទ្ធផលរំពឹងទុក។

៥.៦. ធ្វើរបាយការណ៍យ៉ាងត្រឹមត្រូវ ផ្ដល់ព័ត៌មានយ៉ាងពេញលេញ និងទាន់ពេល ព្រមទាំងប្រើប្រាស់នូវប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រង តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ លើសកម្មភាពដែលបានអនុវត្តដើម្បីរៀបចំ ចងក្រងរក្សាទុកព័ត៌មានទាំងនោះ។

៥.៧. ត្រូវរក្សាទុកនូវរាល់ឯកសារហិរញ្ញវត្ថុច្បាប់ដើមប្រកបដោយភាពពេញលេញ ត្រឹមត្រូវ និងច្បាស់លាស់ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និងគ្រប់គ្រងធនធានហិរញ្ញវត្ថុនានា ដោយរាប់បញ្ចូលទាំងការងារគណនេយ្យ កិច្ចលទ្ធកម្ម កិច្ចសន្យា និងការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការធ្វើសវនកម្ម។

៥.៨. ថវិកាដែលនៅសល់ពីការប្រើប្រាស់ ត្រូវតែបង្វែរត្រឡប់មក **ក្រសួងកសិកម្ម (គម្រោង CoWES)** វិញនៅពេលគម្រោងត្រូវបានបញ្ចប់ជាស្ថាពរ ឬការស្នើឲ្យបង្វិលថវិកាត្រឡប់ក្នុងករណីចាំបាច់ណាមួយ។

៥.៩ **ម្លប់បៃតង** មានសិទ្ធិបត់បែនលើការប្រើប្រាស់ថវិកាតាមលទ្ធផលនីមួយៗ (Output) ក្នុងកម្រិត ១០% (ដប់ភាគរយ) ដោយមិនចាំបាច់ស្នើសុំការយល់ព្រមពី **ក្រសួងកសិកម្ម (គម្រោង CoWES)**។ ទោះជាយ៉ាងណាក្ដី ភាពបត់បែននេះមិនត្រូវលើសពីទឹកប្រាក់សរុបដូចមានចែងក្នុងចំណុច ២.៤ ឡើយ។ ក្នុងករណីសកម្មភាពមានភាពប្រែប្រួលខុសពីផែនការដែលបានឯកភាព **ម្លប់បៃតង** ត្រូវរៀបចំធ្វើ វិសោធនកម្មដូចមានចែងក្នុងចំណុចទី៧ខាងក្រោម។

៥.១០. រៀបចំបូកសរុប ចងក្រង ប្រមូលផ្ដុំឯកសារ ឬព័ត៌មាន និងផ្ដល់លទ្ធភាពគ្រប់ពេលវេលា ក្នុងការឆ្លើយតបដោយផ្ទាល់មាត់ ឬជាលាយល័ក្ខណ៍អក្សរចំពោះការស្នើសុំរបស់ **ក្រសួងកសិកម្ម (គម្រោង CoWES)** ពាក់ព័ន្ធទៅនឹងការអនុវត្តអនុស្សរណៈនេះ។

៥.១១. ជួយសម្រួលដល់ ការធ្វើសវនកម្មផ្ទៃក្នុង និងសវនកម្មឯករាជ្យលើរាល់ការចំណាយផ្នែកហិរញ្ញវត្ថុក្រោម ក្របខ័ណ្ឌនៃអនុស្សរណៈនេះ និងជួយសម្រួលដល់បេសកកម្មរបស់ទីប្រឹក្សានានា និងការត្រួតពិនិត្យរបស់មន្ត្រី **ក្រសួងកសិកម្ម និង គម្រោង CoWES** ។

៥.១២. **ម្លប់បៃតង** ត្រូវបើកគណនីធនាគារចរន្តរបស់ខ្លួនជាប្រាក់ដុល្លារ នៅធានាគារពាណិជ្ជណាមួយដែលមានការទទួលស្គាល់ផ្លូវការពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទទួលថវិកាសម្រាប់អនុវត្តគម្រោងផែនការសកម្មភាព និងថវិកាដែលបានឯកភាពនេះ។

៥.១៣. **ម្លប់បៃតង** មិនត្រូវធ្វើសកម្មភាពណាមួយដើម្បីកេងចំណេញផលប្រយោជន៍ផ្នែកនយោបាយ ឬបម្រើគណបក្សណាឡើយ។

**៦. ការមិនអនុវត្តតាមល័ក្ខខ័ណ្ឌនៃអនុស្សរណៈ:**

ក្នុងករណី **ម្លប់បៃតង** មិនអនុវត្តតាមល័ក្ខខ័ណ្ឌនៃអនុស្សរណៈនេះ **ក្រសួងកសិកម្ម (គម្រោង CoWES)** មានសិទ្ធិប្រកាន់យកនូវវិធានការដូចខាងក្រោម៖

៦.១. តម្រូវឱ្យ **ម្លប់បៃតង** ផ្ទេរនូវមូលនិធិមួយចំនួន ឬទាំងអស់ត្រឡប់មក **ក្រសួងកសិកម្ម** (គម្រោង CoWES) វិញ។

៦.២. ប្រកាន់យកនូវដំណើរការដាក់ពិន័យនានាតាមច្បាប់ចំពោះបុគ្គល ដែលរកឃើញថា បានរំលោភបំពានទៅលើនីតិវិធីដែលបានកំណត់ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន។

**៧. ការធ្វើវិសោធនកម្មអនុស្សរណៈ:**

៧.១. អនុស្សរណៈនេះអាចធ្វើការកែប្រែបានតាមការចាំបាច់ដរាបណាមានការព្រមព្រៀង និងការទទួលស្គាល់ជាលាយល័ក្ខណ៍អក្សរពី **ក្រសួងកសិកម្ម (គម្រោង CoWES)** និង **ម្លប់បៃតង** ប៉ុន្តែការកែប្រែនេះមិនត្រូវផ្ទុយទៅ នឹងឯកសារគម្រោងស្តីពី ការគ្រប់គ្រងរួមគ្នាដើម្បីការពារ និងស្តារសេវាកម្មទីជម្រាល និងប្រព័ន្ធបរិស្ថាននៅតំបន់ជួរភ្នំក្រវាញ (ប៉ែកខាងលើនៃអាងស្ទឹងព្រែកត្នោត) ឬហៅកាត់ថា៖ CoWES ឡើយ។ ក្នុងករណីមានការធ្វើវិសោធនកម្ម **ម្លប់បៃតង** ត្រូវរៀបចំឯកសារដូចខាងក្រោម ៖

- លិខិតស្នើសុំធ្វើវិសោធនកម្មមក **ក្រសួងកសិកម្ម (គម្រោង CoWES)**
- បំពេញទម្រង់ផែនការសកម្មភាព និងថវិកាដែលបញ្ជាក់ពីការប្រែប្រួលនេះ

**៨. ការចុះហត្ថលេខាលើអនុស្សរណៈ:**

អ្នកចុះហត្ថលេខាខាងក្រោមនេះ ជាតំណាងពេញសិទ្ធិរបស់ **ក្រសួងកសិកម្ម (គម្រោង CoWES)** និង**ម្លប់បៃតង** បានព្រមព្រៀងទៅលើល័ក្ខខ័ណ្ឌនានាដែលបានចែងក្នុងអនុស្សរណៈនេះ។

| | |
|---|---|
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**<br>(គម្រោង CoWES) | **អង្គការម្លប់បៃតង** |
| **ឈ្មោះ ៖ បណ្ឌិត មាស ពិសិដ្ឋ** | **ឈ្មោះ ៖ លោក អោម សុផាណា** |
| **មុខងារ ៖** អគ្គលេខាធិការរង និង ជាប្រធានគ្រប់គ្រងគម្រោង | មុខងារ ៖ នាយកប្រតិបត្តិ |
| **ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | **អង្គការម្លប់បៃតង** |